# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ ១៥៨៦ អ.ក
ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១
សាលក្រមលេខ ០៨៦ ស.ព្រ.ឈ/២៣
ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល ។
កាលបរិច្ឆេទសវនាការ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ។
កាលបរិច្ឆេទការប្រកាសសាលក្រមថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ ។

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមជំនុំជម្រះ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង

### ក្រឡាបញ្ជី

លោក [redacted] ក្រឡាបញ្ជីសវនាការ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៥៨៦ អ.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ៖

១. ឈ្មោះ [redacted] **វ៉ាវុធ** ភេទស្រី កើតឆ្នាំ ១៩៨៥ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ អតីតបុគ្គលិកក្រុមហ៊ុន 7NG ទីកន្លែងកំណើតស[redacted] ក្រុងភ្នំពេញ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ [redacted]រាជធានីភ្នំពេញ ឪពុក (ពុំត្រូវបានស្គាល់) ម្ដាយ(ពុំត្រូវបានស្គាល់) ប្ដីឈ្មោះ ជីវ័ន្ត ជានិតិជន ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

២. ឈ្មោះ [redacted] **បញ្ញារិត** ភេទប្រុស កើតឆ្នាំ ១៩៨៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកក្រុមហ៊ុន 7NG ទីកន្លែងកំណើតសង្កាត់[redacted] រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]ណារី (រស់) ម្ដាយឈ្មោះ [redacted] សំណាង (រស់) ប្រពន្ធឈ្មោះ[redacted] សុខារី មានកូន ០១នាក់ ជានីតិជន ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

៣. ឈ្មោះ [redacted] **សុបុត្តា** ភេទប្រុស កើតឆ្នាំ ១៩៩១ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ អាជីវករ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តស្វាយរៀង មានទីលំនៅបច្ចុប្បន្ននៅភូមិស្វាយអាណាត ឃុំញរ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] សាវន (រស់) ម្ដាយឈ្មោះ [redacted] បូរ៉ាវី (ស្លាប់) ប្រពន្ធឈ្មោះ[redacted] ស្រីស្រស់ មានកូន០១នាក់ ជានីតិជន ទោសពីមុន គ្មាន ។ (ក្រៅឃុំ)



Scanned with CamScanner

ត្រូវបានជាប់ចោទពី **បទក្លែងបន្លំ បទប្រើប្រាស់លិខិតក្លែង និង បទលួចលក់អចលនវត្ថុរបស់អ្នកដទៃ** ប្រព្រឹត្តនៅភូមិស្វាយមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ៦២៦ មាត្រា ៦២៧ មាត្រា ៦២៨ នៃ ក្រមព្រហ្មទណ្ឌ និង មាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ណារ៉ែត** ភេទស្រី អាយុ ៤៩ ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន នៅផ្ទះលេខ៣៨x ផ្លូវលេខ៤៨E1 ភូមិត្រពាំងល្វា១ សង្កាត់កាកាប១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **បញ្ញារិត** ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុបុត្តា** ។

- **បានឃើញ** ដីកាដំណោះស្រាយ លេខ ៤៩២ ដកជស ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២ ។

## អង្គហេតុដែលបានចោទប្រកាន់បញ្ជូនមកជំនុំជម្រះ

កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ស្ថិតនៅភូមិស្វាយមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ជនជាប់ចោទឈ្មោះ [redacted] **រ៉ាវុធ** ភេទស្រី កើតឆ្នាំ១៩៨៥ ឈ្មោះ [redacted] **បញ្ញារិត** ភេទប្រុស កើតឆ្នាំ ១៩៨៧ និង ឈ្មោះ [redacted] **សុបុត្តា** ភេទប្រុស កើតឆ្នាំ ១៩៩១ បានរួមគំនិតគ្នាលួចលក់អចលនវត្ថុ(ដី) ចំនួន ៥ឡូតិ៍ ជាដីកម្មសិទ្ធិរបស់ឈ្មោះ [redacted] **ណារ៉ែត** ភេទស្រី អាយុ ៤៩ឆ្នាំ ដែលបានទិញពីក្រុមហ៊ុន 7NG GROUP (តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីលេខ ២៧៤៨/១៨ វ.ហ.ស ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨) ទៅឱ្យឈ្មោះ [redacted] **វ៉ុន** នូវដីឡូតិ៍ ៦៤០a លេខ៦៤១a តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីលេខ៥៥៨/២០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ លក់ឱ្យទៅឈ្មោះ [redacted] **បូរ៉ាត់** នូវដីឡូតិ៍លេខ៦៤២a លេខ ៦៤៣ តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីលេខ ៥៥៩/២០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ និង លក់ទៅឱ្យឈ្មោះ [redacted] **អ៊ាងលី** នូវដីឡូតិ៍លេខ ៦៣៩a ដោយលិខិតផ្ទេរសិទ្ធិលើដីទាំង ៥ឡូតិ៍នេះត្រូវបានធ្វើឡើងដោយក្លែងបន្លំស្នាមមេដៃរបស់ម្ចាស់ដី ដោយការផ្តិតមេដៃដែលគ្មានគុណភាព ហើយយកទៅឱ្យអាជ្ញាធរមូលដ្ឋានចុះហត្ថលេខា និង បោះត្រា ។ ក្នុងការរួមគំនិតគ្នានេះ ឈ្មោះ [redacted] **រ៉ាវុធ** ធ្វើសកម្មភាពជាអ្នករៀបចំឯកសារផ្ទេរសិទ្ធិ និង ឱ្យភាគីផ្តិតស្នាមមេដៃ រីឯឈ្មោះ [redacted] **បញ្ញារិត** ធ្វើសកម្មភាពជាអ្នករត់ការយកលិខិតស្នាមទៅឱ្យអាជ្ញាធរចុះហត្ថលេខា និង បោះត្រា ចំណែកឈ្មោះ [redacted] **សុបុត្តា** ធ្វើសកម្មភាពជាអ្នកនាំអតិថិជនមកទិញដី និង ទទួលប្រាក់ពីអតិថិជន ។ បន្ទាប់ពីបានដឹងរឿងហេតុខាងលើឈ្មោះ [redacted] **ណារ៉ែត** បានទៅជួបអាជ្ញាធរមូលដ្ឋាន ដើម្បីសុំមោឃភាពលិខិតផ្ទេរសិទ្ធិដែលក្លែងបន្លំខាងលើ ហើយនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ម្ចាស់ដីឈ្មោះ [redacted] **ណារ៉ែត** បានដាក់ពាក្យបណ្តឹងប្តឹងឈ្មោះ [redacted] **រ៉ាវុធ** និង បក្ខពួក មកកាន់អយ្យការអមសាលាដំបូងខេត្តកណ្តាល ដើម្បីចាត់ការតាមច្បាប់ ។

## ដំណើរការនៃកិច្ចពិភាក្សាដេញដោល

១. ជនជាប់ចោទឈ្មោះ [redacted] **សុបុត្តា** បានឆ្លើយនៅចំពោះមុខតុលាការថា ៖ ខ្ញុំបាទមិនទទួលស្គាល់អង្គហេតុដែលបានចោទប្រកាន់មកលើរូបខ្ញុំនោះទេ ។ ខ្ញុំបាទមិនបានឃុបឃិតជាមួយឈ្មោះ [redacted] **រ៉ាវុធ** និង ឈ្មោះ [redacted] **បញ្ញារិត** នោះទេ ។ ខ្ញុំធ្លាប់ជាបុគ្គលិកធ្វើការនៅក្រុមហ៊ុននោះ គឺលើកទី១ ចាប់ពីឆ្នាំ ២០១៥ ដល់ឆ្នាំ២០១៧ ខ្ញុំមានតួនាទីជាស្ថាបត្យករ ខ្ញុំបានសុំឈប់ លើកទី២ ក្រុមហ៊ុនបានហៅខ្ញុំទៅធ្វើការម្តងទៀតនៅក្នុងឆ្នាំ២០១៨ ដែលពេលនោះខ្ញុំធ្វើការ ក្នុងតួនាទីផ្នែកលក់នៅ



Scanned with CamScanner

សាខាអរិយក្សត្រ ដែលមានលោកឧកញ៉ាស្រីចន្ទជាអ្នកទទួលខុសត្រូវ ខាងសាខាអរិយក្សត្រនោះ លុះដល់ឆ្នាំ២០១៩ ខ្ញុំក៏បានឈប់ម្តងទៀត ។ ខ្ញុំបាទធ្លាប់ជាបុគ្គលិកនៅក្រុមហ៊ុន 7អិនធី តែមិនមែន ធ្វើនៅសាខាធំជាមួយឈ្មោះ [redacted] **រ៉ាវុធ** ធ្វើនៅការនោះទេ ។ ខ្ញុំស្គាល់ឈ្មោះ [redacted] **រ៉ាវុធ** តាមរយៈបុគ្គលិកធ្វើការជាមួយគ្នាផ្សេងទៀត ដែលដឹងថាឈ្មោះនេះជាអ្នកទិញដីពីភ្ញៀវ ដែលមានដីលក់ ហើយ លក់ទៅឱ្យភ្ញៀវដែលចង់ទិញដីនោះ ដូចនេះគឺអាចទៅទិញលក់ដីតាមរយៈឈ្មោះ [redacted] **រ៉ាវុធ** បាន ។ នៅពេលនោះខ្ញុំមានភ្ញៀវចង់ទិញដី ក៏បាននាំទៅទិញដីពីឈ្មោះ [redacted] **រ៉ាវុធ** ដែលជាបុគ្គលិករបស់ ក្រុមហ៊ុន៧អិនធី នេះហើយដីដែលខ្ញុំនាំភ្ញៀវទៅទិញនោះ គឺជាដីរបស់ឈ្មោះ [redacted] **ណារៃណេត** ដែលឈ្មោះ [redacted] **រ៉ាវុធ** បានប្រាប់ខ្ញុំ ។ ខ្ញុំគ្រាន់តែជាអ្នកនាំភ្ញៀវមកទិញដីនោះ ដោយបានកម្រៃជើងសារចំនួន ៣%(បីភាគរយ)នៃដីមួយឡូតិ៍ ។ នៅចុងឆ្នាំ២០២០ និង ដើមឆ្នាំ២០២១ គឺជាពេលដែលទិញលក់ដីនោះ ។ ពេលដែលជួបគ្នាប្រគល់លុយទិញដីនោះ គឺបានណាត់មកជួបគ្នានៅក្នុងការិយាល័យលក់របស់ក្រុមហ៊ុន៧អិនធីតែម្តង តែពេលនោះមិនបានឃើញឈ្មោះ [redacted] **ណារៃណេត** មកនោះទេ តែក្នុងឯកសារលិខិតផ្ទេរសិទ្ធិ នោះគឺខ្ញុំ ឃើញមានស្នាមមេដៃរបស់អ្នកលក់ ស្នាមមេដៃសាក្សី ព្រមទាំងមានហត្ថលេខា និង ត្រា របស់អាជ្ញាធរភូមិឃុំ ។ ឯកសារលិខិតផ្ទេរសិទ្ធិដី ពីឈ្មោះ [redacted] **ណារៃណេត** ទៅឱ្យឈ្មោះ [redacted] **បូរ៉ាត់** គឺឈ្មោះ [redacted] **រ៉ាវុធ** ជាអ្នករត់ការផ្ទេរសិទ្ធិ ហើយខ្ញុំមិនដឹងថាឈ្មោះ [redacted] **រ៉ាវុធ** បានយកឯកសារនោះទៅឱ្យម្ចាស់ដីពេលណានោះទេ គឺគ្រាន់តែឃើញឯកសារនោះនៅឈ្មោះ [redacted] **រ៉ាវុធ** ។ ភ្ញៀវដែលខ្ញុំនាំមកទិញដីគឺឈ្មោះ [redacted] **បូរ៉ាត** គឺបានមកប្រគល់លុយ និង ផ្តិតមេដៃនៅក្នុងការិយាល័យក្រុមហ៊ុនចំពោះមុខក្រុមការងារតែម្តង ។ ខ្ញុំយកប្រាក់ពីអ្នកទិញដីទៅឱ្យ ឈ្មោះ [redacted] **រ៉ាវុធ** ដោយសារឈ្មោះ [redacted] **រ៉ាវុធ** នាំយកលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីច្បាប់ដើម ផ្ទេរពីអ្នកលក់មកឈ្មោះអ្នកទិញ និង មានអាជ្ញាធរភូមិឃុំចុះហត្ថលេខា និង បោះត្រាត្រឹមត្រូវមកបង្ហាញខ្ញុំបាទ ទើបខ្ញុំទទួលប្រាក់ពី អ្នកទិញដីមកទូទាត់ថ្លៃដីឱ្យឈ្មោះ [redacted] **រ៉ាវុធ** តែម្តង ។ ចំពោះអ្នកទិញដី និង អ្នកលក់ដី ខ្ញុំបាទដឹងថាអ្នកនោះត្រូវទៅផ្តិតមេដៃនៅចំពោះមុខឈ្មោះ [redacted] **បញ្ញារិត** ទើបឈ្មោះ [redacted] **បញ្ញារិត** និង ឈ្មោះ [redacted] **រ៉ាវុធ** ជាអ្នកដឹងច្បាស់ ចំណែកខ្ញុំបាទពុំបានដឹងទេ ដោយខ្ញុំគ្រាន់តែជាអ្នកនាំភ្ញៀវ មកទិញដីប៉ុណ្ណោះ ។ ការប្រគល់លុយថ្លៃទិញដីមកឱ្យខ្ញុំ គឺខ្ញុំពុំបានធ្វើវិក័យបត្រទេ ហើយការប្រគល់លុយពីខ្ញុំ ទៅឱ្យឈ្មោះ [redacted] **រ៉ាវុធ** និង ឈ្មោះ [redacted] **បញ្ញារិត** ក៏ពុំបានធ្វើវិក័យបត្រដែរ ដោយសារខ្ញុំគិតថាពុំចាំបាច់ ។

២. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ណារៃណេត** បានឆ្លើយនៅចំពោះមុខតុលាការថា ៖ នាងខ្ញុំស្នើសុំប្តឹងទាមទារថ្លៃដីទាំង ៥ ឡូតិ៍ ចំនួន ៥ (ប្រាំ) ម៉ឺនដុល្លារអាមេរិក និង ជម្ងឺចិត្តចំនួន ១ (មួយ) ម៉ឺនដុល្លារអាមេរិក ។ ខ្ញុំទិញដីពីក្រុមហ៊ុនផ្ទាល់ គឺ ពីឈ្មោះ [redacted] **សុធា** ដែលមានត្រាក្រុមហ៊ុន ។ នាងខ្ញុំប្តឹងជនជាប់ចោទឈ្មោះ [redacted] **រ៉ាវុធ** ឈ្មោះ [redacted] **បញ្ញារិត** មេភូមិ និង មេឃុំ ដោយឡែកខ្ញុំមិនប្តឹងអ្នកដែលនាំភ្ញៀវឈ្មោះ [redacted] **សុបុត្តា** មកទិញដីនោះទេ ។ ខ្ញុំមិនដែលស្គាល់ និង ឃើញឈ្មោះ [redacted] **សុបុត្តា** នេះទេ ។ ដីនេះនាងខ្ញុំបានទិញពីក្រុមហ៊ុន ៧អិនធី ។ ខ្ញុំទិញរយៈពេល ១០ (ដប់) ឆ្នាំ ក្នុងតម្លៃសរុប ១.៨០០ (មួយពាន់ប្រាំបីរយ) ដុល្លារអាមេរិកក្នុង១ឡូតិ៍ ក្នុងឆ្នាំ ២០០៧ ដោយបង់រំលោះសរុប ១២០ ខែ ។ ជនជាប់ចោទដែលខ្ញុំប្តឹងខាងលើ គឺលក់ដីរបស់ខ្ញុំ ទាំង ៥ ឡូតិ៍ ។ នៅក្នុងខែមីនា ឆ្នាំ២០២១ ខ្ញុំឃើញគេធ្វើរបង និង តទឹកចូល នៅលើដីខ្ញុំ ខ្ញុំក៏ទៅរកក្រុមហ៊ុន តែក្រុមហ៊ុនថាមិនដឹង ហើយខ្ញុំក៏បានទៅរកអាជ្ញាធរ ។ ខ្ញុំស្គាល់តែឈ្មោះ [redacted] **រ៉ាវុធ** ដែលជាអ្នកទទួលបង់ថ្លៃដីនៅក្នុងក្រុមហ៊ុន ។ ខ្ញុំមិនស្គាល់ឈ្មោះ [redacted] **បញ្ញារិត** ទេ ។ មូលហេតុ ដែលនាងខ្ញុំប្តឹងឈ្មោះ [redacted] **បញ្ញារិត**

គឺមកពីមានឈ្មោះ [redacted] បញ្ញារិត នៅក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់ ។ បច្ចុប្បន្នលិខិតផ្ទេរសិទ្ធិកាន់កាប់ពីក្រុមហ៊ុន គឺនៅជាមួយខ្ញុំរាល់ថ្ងៃ ។ នៅក្នុងរឿងនេះខ្ញុំធ្លាប់បានពឹង ឈ្មោះ [redacted] វ៉ាវុធ ជួយលក់ដីនោះវិញនៅពេលដែលបានទិញពីក្រុមហ៊ុនរួចហើយ ។ ខ្ញុំមិនធ្លាប់បានផ្តិតមេដៃលើការទិញលក់ ឬ មិនធ្លាប់ផ្តិតមេដៃលើក្រដាសទុកឱ្យឈ្មោះ [redacted] វ៉ាវុធ នោះទេ ។ មកដល់ឆ្នាំ២០២០ ឈ្មោះ [redacted] វ៉ាវុធ បានប្រាប់ថាមានគេចង់ទិញដីរបស់ខ្ញុំ ខ្ញុំក៏បានឯកភាព និង ទទួលបានលុយកក់ពីឈ្មោះ [redacted] វ៉ាវុធ បានឱ្យវេរលុយកក់មកខ្ញុំចំនួន ពីរលើកគត់ គឺលើកទី១ ចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក និង លើកទី២ ចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក សរុបចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិកគត់ បន្ទាប់ពីនោះគឺមិនទទួលបានប្រាក់ទៀតនោះទេ ។ នៅក្នុងរឿងនេះនាងខ្ញុំសូមប្តឹងទាមទារថ្លៃដីចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លាអាមេរិក និង ជម្ងឺចិត្តចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ។

៣. អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បញ្ញារិត បានឆ្លើយនៅដំណាក់កាលអយ្យការថា ៖ ខ្ញុំបាទជាបុគ្គលិកបំរើការងារនៅក្នុងក្រុមហ៊ុន7NG ស្ថិតនៅឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល បំរើការងារផ្នែករដ្ឋបាលការដ្ឋាន នៃក្រុមហ៊ុនខាងលើ ។ ខ្ញុំបាទបំរើការងារនៅក្រុមហ៊ុនខាងលើពុំមានកាតសម្គាល់ខ្លួនទេ រាល់ការបើកប្រាក់ខែ បើកតាមស្រោមសំបុត្រ ខ្ញុំបំរើការងារនេះរយៈពេល៦ឆ្នាំមកហើយ ។ ខ្ញុំបាទធ្លាប់ឃើញស្គាល់ឈ្មោះ [redacted] ណារ៉ែណេត នោះទេ ។ ខ្ញុំបាទទទួលស្គាល់ថាដីឡូតិ៍លេខ ៦៣៩អា ៦៤០អា ៦៤១អា ៦៤២អា ៦៤៣អា ក្នុងប្លុកZ នៅក្នុងក្រុមហ៊ុន7NG ស្ថិតនៅភូមិស្វាយមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល នៅក្នុងស៊ីស្ទឹមរបស់ក្រុមហ៊ុន ដីឡូតិ៍ខាងលើជារបស់ឈ្មោះ [redacted] ណារ៉ែណេត លក់ដីឡូតិ៍លេខ ៦៤២អា លេខ ៦៤៣អា បន្តទៅឱ្យឈ្មោះ [redacted] បូរ៉ាត់ និង ឈ្មោះ [redacted] ណារ៉ែណេត លក់ដីឡូតិ៍លេខ៦៤០អា លេខ ៦៤១អា បន្តទៅឱ្យឈ្មោះ [redacted] វ៉ុន នោះ ខ្ញុំបាទមិនទទួលស្គាល់ស្នាមមេដៃផ្តិតត្រង់កន្លែងសាក្សីអ្នកទទួលសិទ្ធិដែលមានឈ្មោះខ្ញុំនោះទេ ថាជាស្នាមមេដៃរបស់ខ្ញុំនោះទេ ព្រោះថាស្នាមមេដៃនោះផ្តិតពុំមានស្នាមក្រយៅដៃទេ ។ ខ្ញុំបាទពុំស្គាល់ឈ្មោះ [redacted] បូរ៉ាត់ និង ឈ្មោះ ជុំ វ៉ុន ដែលជាអ្នកទិញដីពីឈ្មោះ [redacted] ណារ៉ែណេត ទេ ។ បច្ចុប្បន្នខ្ញុំមិនដឹងថាដីរបស់ឈ្មោះ [redacted] ណារ៉ែណេត បានលក់បន្ត ឬ មិនបានលក់បន្តនោះទេ ព្រោះខ្ញុំបាទក្តាប់ស៊ីស្ទឹមរបស់ក្រុមហ៊ុនបានត្រឹមតែពីការលក់ដីរបស់ក្រុមហ៊ុនបន្តទៅឱ្យអ្នកទិញដីទីមួយពីខាងក្រុមហ៊ុនប៉ុណ្ណោះ ។ កន្លងមកខ្ញុំបាទធ្លាប់ផ្តិតមេដៃធ្វើជាសាក្សីដឹងឮលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីឱ្យអ្នកទិញលក់ដីនៅក្នុងក្រុមហ៊ុន 7NG ជាច្រើនដងមកហើយ ដោយចាំមិនអស់នោះទេ ។ ចំពោះការទិញលក់ដីរវាងម្ចាស់ដីដើមជាមួយអ្នកទិញដីនៅក្នុងក្រុមហ៊ុន 7NG កន្លងមកនោះ ខ្ញុំបាទពុំបានដឹងថាមានការចុះវាស់វែងពីអាជ្ញាធរ ឬ ពីអ្នកលក់អ្នកទិញដីនោះទេ ។ ខ្ញុំបាទគ្រាន់តែដឹងថា ឈ្មោះ [redacted] វ៉ាវុធ ជាបុគ្គលិកផ្នែកលក់នៅក្នុងក្រុមហ៊ុន 7NG ចំពោះមុខងារគាត់ផ្សេងទៀត ខ្ញុំបាទពុំបានដឹងទេ ។ ខ្ញុំបាទពុំអាចទំនាក់ទំនងឈ្មោះ [redacted] វ៉ាវុធ បានទេ ដោយហេតុថាឈ្មោះ [redacted] វ៉ាវុធ ត្រូវបានក្រុមហ៊ុនបញ្ឈប់កាលពីចុងឆ្នាំ ២០២១ ដោយសារផ្ទុះរឿងមានគេប្តឹងពីឈ្មោះ [redacted] វ៉ាវុធ ពីរឿងដែលគាត់លក់ដីឱ្យគេហើយ អត់បានប្រាក់ឱ្យម្ចាស់ដី ។

៤. អំណានចម្លើយរបស់ឈ្មោះ [redacted] បូរ៉ាត់ បានឆ្លើយថានៅដំណាក់កាលអយ្យការ ៖ ដីឡូតិ៍លេខ ៦៤២អា ៦៤៣អា ខ្ញុំបាទពិតជាបានទិញពីម្ចាស់ដីឈ្មោះ [redacted] ណារ៉ែណេត ពិតមែន តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដី ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ប៉ុន្តែខ្ញុំបាទពុំដែលស្គាល់ឈ្មោះ [redacted] ណារ៉ែណេត នេះពីមុនមកទេ ព្រោះខ្ញុំបាទទិញដីខាងលើតាមរយៈឈ្មោះ [redacted] សុបុត្តា ។



Scanned with CamScanner

ចំពោះឈ្មោះ [redacted] **សុបុត្តា** គាត់ជាអ្នកគក់ជេរដីនៅក្នុងក្រុមហ៊ុន 7NG នោះ គាត់ពុំត្រូវជាអ្វីជាមួយខ្ញុំនោះទេ ។ ចំពោះការទិញដីនេះ ខ្ញុំបាទទិញក្នុងតម្លៃ ៣.០០០ (បីពាន់)ដុល្លារអាមេរិក ក្នុងមួយឡូតិ៍ ដោយខ្ញុំបាទប្រគល់ប្រាក់ថ្លៃដីតាមរយៈឈ្មោះ [redacted] **សុបុត្តា** និង មានធ្វើជាក្រដាសស្នាមផងដែរ តែខ្ញុំបាទពុំបានភ្ជាប់មកជាមួយនោះទេ ។ ខ្ញុំបាទពុំបានជួបផ្ទាល់ជាមួយម្ចាស់ដីដើមឈ្មោះ [redacted] **ណាណែត** នោះទេ ។ ខ្ញុំពឹងពាក់ឱ្យឈ្មោះ [redacted] **សុបុត្តា** ជាអ្នករត់ការផ្ទេរសិទ្ធិដីនេះមកឱ្យខ្ញុំ ហើយខ្ញុំទៅផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីនេះនៅក្នុងក្រុមហ៊ុន 7NG ដោយខ្ញុំបាទផ្តិតមេដៃចុងក្រោយគេហើយ មុនខ្ញុំបាទផ្តិតមេដៃខ្ញុំពិនិត្យឃើញថា ក្នុងលិខិតផ្ទេរសិទ្ធិមានស្នាមមេដៃ របស់អ្នកលក់ដីឈ្មោះ [redacted] **ណាណែត** ស្នាមមេដៃសាក្សីឈ្មោះ [redacted] **រ៉ាវុធ** ឈ្មោះ [redacted] **បញ្ញារិត** និង មានហត្ថលេខាប្រថាប់ត្រារបស់អាជ្ញាធរភូមិឃុំរួចជាស្រេចហើយ ទើបខ្ញុំផ្តិតមេដៃទៅចំពោះមុខឈ្មោះ [redacted] **សុបុត្តា** និង អ្នកដទៃទៀតនៅទីនោះខ្ញុំមិនស្គាល់ឈ្មោះ ។ ចំពោះការទិញដីនេះ ខ្ញុំបាទបានផ្តិតមេដៃតែលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីតែម្តងប៉ុណ្ណោះ ពុំធ្លាប់ផ្តិតលើលិខិតស្នាមអ្វីទៀតនោះទេ ។ ចំពោះស្នាមមេដៃអ្នកទទួលសិទ្ធិ ក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដី ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ពិតជាស្នាមមេដៃរបស់ខ្ញុំបាទ ហើយខ្ញុំពិតជាបានទិញដីឡូតិ៍លេខ ៦៤២អា ៦៤៣អា នៅក្នុងក្រុមហ៊ុន 7NG ពិតមែន ។ បន្ទាប់ពីទិញដីនេះមកបានប្រហែលពីរបីខែក្រោយ ខ្ញុំបានលក់ដីទាំងពីរឡូតិ៍លេខ ៦៤២អា ៦៤៣អា នេះបន្តទៅឱ្យឈ្មោះ [redacted] **ទិត្យមករា** ភេទប្រុស អាយុប្រហែលសាមសិបបួនឆ្នាំ បច្ចុប្បន្នឈ្មោះ [redacted] **ទិត្យមករា** គាត់រស់នៅទីតាំងដីនោះ ហើយខ្ញុំលក់ដីខ្ញុំឱ្យឈ្មោះ [redacted] **ទិត្យមករា** ក្នុងតម្លៃ ៤.៥០០ (បួនពាន់ប្រាំរយ) អាមេរិក ក្នុងមួយឡូតិ៍ ហើយឈ្មោះ [redacted] **ទិត្យមករា** បានប្រគល់ប្រាក់មកឱ្យខ្ញុំនៅក្នុងក្រុមហ៊ុន 7NG តែម្តង ។ ខ្ញុំបាទពុំដែលស្គាល់ឈ្មោះ [redacted] **បញ្ញារិត** និង ឈ្មោះ [redacted] **រ៉ាវុធ** នោះទេ ហើយក៏ពុំដែលឮឈ្មោះ [redacted] **សុបុត្តា** និយាយពីឈ្មោះ [redacted] **រ៉ាវុធ** និង ឈ្មោះ [redacted] **បញ្ញារិត** ឡើយ ។

៥. អំណានចម្លើយរបស់ឈ្មោះ [redacted]ុន បានឆ្លើយនៅដំណាក់កាលអយ្យការ ៖ ដីឡូតិ៍លេខ ៦៤០អា ៦៤១អា ខ្ញុំបាទពិតជាបានទិញពីម្ចាស់ដីឈ្មោះ [redacted] **ណាណែត** ពិតមែន តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ប៉ុន្តែខ្ញុំបាទពុំដែលស្គាល់ឈ្មោះ [redacted] **ណាណែត** នេះពីមុនមកទេ ព្រោះខ្ញុំបាទទិញដីខាងលើតាមរយៈឈ្មោះ [redacted] **សុបុត្តា** និង ឈ្មោះ [redacted] **រ៉ាវុធ** ។ ចំពោះឈ្មោះ [redacted] **សុបុត្តា** គាត់ជាអ្នកគក់ជេរដីនៅក្នុងក្រុមហ៊ុន 7NG នោះ គាត់ពុំត្រូវជាអ្វីជាមួយខ្ញុំនោះទេ ។ ចំពោះការទិញដីនេះ ខ្ញុំបាទទិញក្នុងតម្លៃ ៣.០០០ (បីពាន់ដុល្លារ) អាមេរិក ក្នុងមួយឡូតិ៍ ដោយខ្ញុំបានប្រគល់ប្រាក់ថ្លៃដីតាមរយៈឈ្មោះ [redacted] **សុបត្តា** និង មានធ្វើជាក្រដាសស្នាមផងដែរ តែខ្ញុំបាទពុំបានភ្ជាប់មកជាមួយនោះទេ ។ ខ្ញុំបាទពុំបានជួបផ្ទាល់ជាមួយម្ចាស់ដីដើមនោះទេ ។ ខ្ញុំបាទពឹងពាក់ឱ្យឈ្មោះ [redacted] **សុបុត្តា** ជាអ្នករត់ការផ្ទេរសិទ្ធិដីនេះមកឱ្យខ្ញុំ ហើយឈ្មោះ [redacted] **សុបុត្តា** ក៏ជាអ្នកយកលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីនេះ មកឱ្យខ្ញុំបាទផ្តិតមេដៃផ្ទាល់ដោយខ្ញុំបាទផ្តិតមេដៃផ្ទាល់ ដោយខ្ញុំបាទផ្តិតមេដៃចុងក្រោយគេ ដោយមិនខ្ញុំបាទផ្តិតមេដៃខ្ញុំពិនិត្យឃើញថា ក្នុងលិខិតផ្ទេរសិទ្ធិមានស្នាមមេដៃរបស់អ្នកលក់ដីឈ្មោះ [redacted] **ណាណែត** ស្នាមមេដៃសាក្សីឈ្មោះ [redacted] **រ៉ាវុធ** ឈ្មោះ [redacted] **បញ្ញារិត** និង មានហត្ថលេខាប្រថាប់ត្រារបស់អាជ្ញាធរភូមិឃុំរួចជាស្រេចហើយ ទើបខ្ញុំផ្តិតមេដៃទៅ ប៉ុន្តែខ្ញុំបាទពុំចាំផ្តិតនៅកន្លែងពេលណានោះទេ ។ ចំពោះការទិញដីនេះ ខ្ញុំបាទបានផ្តិតមេដៃតែលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីប៉ុណ្ណោះ ហើយផ្តិតមេដៃចំពោះមុខឈ្មោះ [redacted] **សុបុត្តា** តែម្នាក់ប៉ុណ្ណោះ ។ ខ្ញុំបាទទទួលស្គាល់ថា ស្នាមមេដៃអ្នកទទួលសិទ្ធិក្នុងលិខិត



Scanned with CamScanner

ផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដី ចុះថ្ងៃ១២ ខែវិច្ឆិកា ឆ្នាំ២០២០ ពិតជាស្នាមមេដៃរបស់ខ្ញុំបាទពិតមែន ។ បន្ទាប់ពីទិញដីនេះមក ខ្ញុំបាទបានរត់ការដល់អាជ្ញាធរមានសមត្ថកិច្ច ចេញបានជាប្លង់រឹងរួចហើយ ទើបខ្ញុំបានលក់ដីទាំងពីរឡូត៍លេខ ៦៤០អា ៦៤១អា នេះបន្តទៅឱ្យឈ្មោះ [redacted] ទិត្យមករា ភេទប្រុស អាយុប្រហែល ៤៣ឆ្នាំ មានទីលំនៅ(មិនចាំ) ក្នុងតម្លៃ ៣.៤០០ (បីពាន់បួនរយ) ដុល្លារអាមេរិក ក្នុងមួយឡូត៍ ដោយខ្ញុំ និង ប្រពន្ធខ្ញុំបានយកប្រាក់ទៅប្រគល់នៅក្នុងក្រុមហ៊ុន 7NG ទៅឱ្យឈ្មោះ [redacted] សុបុត្តា និង ស្ត្រីម្នាក់ទៀតខ្ញុំមិនស្គាល់ឈ្មោះ ។ ខ្ញុំបាទពុំដែលស្គាល់ឈ្មោះ [redacted] បញ្ញារិត និង ឈ្មោះ [redacted] វ៉ារុធ នោះទេ ។

៦. អំណានចម្លើយរបស់ឈ្មោះ [redacted] ហុន បានឆ្លើយនៅដំណាក់កាលអយ្យការ ៖ ខ្ញុំបាទសូមជម្រាបថា ចំពោះដីនៅក្នុងក្រុមហ៊ុន 7NG ស្ថិតនៅភូមិស្វាយមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ក្នុងនាមខ្ញុំជាអាជ្ញាធរភូមិស្វាយមាស ពិតជាបានចុះហត្ថលេខាបញ្ជាក់ពីការទិញលក់ដី រវាងម្ចាស់ដីឈ្មោះ [redacted] ណារ៉ៃណេត លក់ដីឡូត៍លេខ៦៤០អា ៦៤១អា ក្នុងប្លុកZទៅឱ្យអ្នកទិញដីឈ្មោះ [redacted] ប៉ូរ៉ាត់ លើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដី ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ពិតមែន ។ ចំពោះលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីខាងលើ ខ្ញុំបាទពុំបានចាំថាអ្នកទិញដី ឬ អ្នកលក់ដី ឬ ខាងក្រុមហ៊ុន ជាអ្នកយកមកឱ្យខ្ញុំចុះហត្ថលេខានោះទេ ព្រោះមានលិខិតច្រើនពេក ខ្ញុំចាំពុំបាន។ ខ្ញុំបាទសូមបញ្ជាក់ថា ចំពោះការទិញលក់ដីនៅក្នុងក្រុមហ៊ុន 7NG អាជ្ញាធរភូមិឃុំខ្ញុំពុំអាចចូលទៅធ្វើការវាស់វែងបានទេ ព្រោះខាងក្រុមហ៊ុនជាអ្នកចាត់ចែងរៀបចំទាំងអស់ជាមួយម្ចាស់ដី និង អ្នកទិញដី ។ ចំពោះឯកសារលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដី គឺខាងក្រុមហ៊ុន 7NG ជាអ្នករៀបចំឡើយ ពុំមែនជាទម្រង់របស់ភូមិឃុំឡើយ ។ រាល់លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីទាំងអស់ ហើយនៅពេលខ្ញុំពិនិត្យឃើញឯកសារផ្ទេរសិទ្ធិនោះធ្វើឡើងមានស្នាមមេដៃអ្នកលក់ដី អ្នកទិញដី និង សាក្សីដឹងឮអស់ហើយ ខ្ញុំក៏ចុះហត្ថលេខាឱ្យទៅ ។ ខ្ញុំបាទសូមបញ្ជាក់បន្ថែមថានៅពេលភាគីអ្នកទិញដី និង អ្នកលក់ដី ព្រមព្រៀងគ្នាទិញលក់ដីនៅក្នុងក្រុមហ៊ុន 7NG ខាងលើ ទាំងអ្នកទិញដី អ្នកលក់ដី និង សាក្សីដឹងឮ ពុំបានផ្ដិតមេដៃលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីនៅចំពោះមុខអាជ្ញាធរភូមិឃុំឡើយ គឺអ្វីៗទាំងអស់ខាងក្រុមហ៊ុនជាអ្នករៀបចំ ដោយនៅពេលអ្នកទិញដី ឬ អ្នកលក់ដី យកលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីមកសុំហត្ថលេខាពីអាជ្ញាធរភូមិឃុំ គឺទម្រង់លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដី ត្រូវបានបំពេញ និង មានស្នាមមេដៃអ្នកលក់ដី អ្នកទិញដី និង សាក្សីដឹងឮស្រាប់ហើយ ដោយពួកគាត់យកលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីមកចំនួន ៣ ច្បាប់ ហើយពុំមានភ្ជាប់មកជាមួយកិច្ចសន្យា ឬកិច្ចព្រមព្រៀង ឬ លិខិតលក់ទិញអ្វីឡើយ ។ ចំពោះឈ្មោះ [redacted] វ៉ារុធ និង ឈ្មោះ [redacted] បញ្ញារិត ខ្ញុំបាទពុំដែលស្គាល់នោះទេ ហើយរាល់លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដី ដែលចេញពីខាងក្រុមហ៊ុន 7NG ស្ថិតនៅក្នុងប្លុក Z នៅពេលខ្ញុំពិនិត្យលើលិខិតនោះឃើញថាមានស្នាមមេដៃអ្នកលក់ អ្នកទិញ និង សាក្សីគ្រប់ចំនួនហើយ ខ្ញុំបាទក្នុងនាមជាអាជ្ញាធរភូមិស្វាយមាស ក៏ចុះហត្ថលេខាជូនតែម្ដង ដោយពុំបានដឹងថាស្នាមមេដៃរបស់អ្នកទិញដី អ្នកលក់ដី និង សាក្សីដឹងឮនោះក្លែងឬមិនក្លែងនោះទេ ។

៧. តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា ៖ ក្រោយការឆ្លងកាត់ការពិភាក្សាដេញដោលយល់ឃើញថា ជនជាប់ចោទចំនួនបីនាក់ ក្នុងឋានៈជាសហចារីបានឃុបឃិតគ្នាលួចយកអចលនវត្ថុរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណារ៉ៃណេត យកទៅលក់ឱ្យអ្នកដទៃ ។ នៅក្នុងសកម្មភាពនៃការលួចលក់នោះគឺ ជនជាប់ចោទមួយរូបដែលធ្វើការនៅក្នុងក្រុមហ៊ុន៧អិនជី បានឃុបឃិតគ្នា



Scanned with CamScanner

ដោយជនជាប់ចោទ ឈ្មោះ [redacted] រ៉ាវុធ បានដើរតួនាទីជាអ្នករៀបចំឯកសារផ្ទេរកម្មសិទ្ធិ ជនជាប់ចោទ ឈ្មោះ [redacted] បញ្ញារិត ដើរតួនាទីជាអ្នកនាំយកឯកសារផ្ទេរសិទ្ធិ និង ឯកសារពាក់ព័ន្ធទាំងឡាយ យកទៅឱ្យអាជ្ញាធរភូមិឃុំចុះហត្ថលេខា និង បោះត្រា ចំណែកឯជនជាប់ចោទ ឈ្មោះ [redacted] សុបុត្តា បានដើរតួនាទីជាអ្នកនាំអតិថិជនដែលមានបំណងទិញ ឬ លក់ដី ឱ្យទៅជួបឈ្មោះ [redacted] រ៉ាវុធ និង ឈ្មោះ [redacted] បញ្ញារិត ដើម្បីទិញឬលក់ដីនោះ ។ ដីដែល ជនជាប់ចោទ ទាំងបីនាក់បានឃុបឃិតគ្នាទិញដីនោះ គឺជារបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយការទិញលក់ដីនេះ គឺពុំមានវត្តមានរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទេ ហើយក៏ពុំមានលិខិតស្នាមច្បាប់ដើមផងដែរ ។ ជនជាប់ចោទឈ្មោះ [redacted] សុបុត្តា បានឆ្លើយថាខ្លួនបានឈប់ធ្វើការនៅក្រុមហ៊ុន ហើយប៉ុន្តែពុំមានភស្តុតាងណាមួយបញ្ជាក់ថាខ្លួនពិតជាបានឈប់ធ្វើការ លែងជាបុគ្គលិកក្រុមហ៊ុន តាំងពីពេលណា មកនោះទេ ? ដែលចម្លើយនេះគឺគ្រាន់តែជាលេស ដើម្បីគេចវេសពីការទទួលខុសត្រូវព្រហ្មទណ្ឌ តែប៉ុណ្ណោះ ។ ដោយឡែកអាជ្ញាធរមូលដ្ឋានភូមិឃុំពុំមានសមត្ថកិច្ច ឬសិទ្ធិណាមួយដើម្បីបញ្ជាក់ ឯកសារលើការទិញលក់ដីរបស់ភាគីនោះទេ ដូចនេះការដែរភាគីទិញលក់ដីយកឯកសារទិញលក់ដីទៅឱ្យអាជ្ញាធរមូលដ្ឋានភូមិឃុំ បញ្ជាក់នោះគឺពុំមែនជាកំហុសរបស់អាជ្ញាធរមូលដ្ឋានភូមិឃុំទេ តែនេះគ្រាន់តែជាកំហុសរដ្ឋបាលរបស់អាជ្ញាធរមូលដ្ឋានភូមិឃុំតែប៉ុណ្ណោះ ។ ឯកសារទិញលក់នៅក្នុង ក្រុមហ៊ុន៧អិនជី មិនមែនធ្វើឡើងដោយអាជ្ញាធរមូលដ្ឋានភូមិឃុំនោះទេ គឺទម្រង់ឯកសារទាំងអស់ធ្វើឡើងដោយជនជាប់ចោទ ហើយអាជ្ញាធរមូលដ្ឋានភូមិឃុំមិនមែនជាអ្នករៀបចំឯកសារ ឬចុះហត្ថលេខាប្រថាប់ត្រាទុកមុននោះទេ ។ តំណាងអយ្យការស្នើសុំរក្សាការចោទប្រកាន់ដូចមាននៅក្នុង ដីកាសន្និដ្ឋានស្ថាពរដដែល ដោយស្នើសុំផ្តន្ទាទោសជនជាប់ចោទទាំងបីនាក់ ពីបទក្លែងបន្លំ ប្រើប្រាស់លិខិតក្លែង និង លួចលក់អចលនវត្ថុរបស់អ្នកដទៃ និង ស្នើសុំតុលាការចេញដីកាចាប់ខ្លួនជនជាប់ចោទ ទាំងបីនាក់ មកអនុវត្តន៍ទោសតាមច្បាប់ ។

៨. លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន ៖ បន្ទាប់ពីបានស្តាប់ការពិភាក្សាដេញដោលក្នុងអង្គសវនាការ នោះគឺកូនក្តីរបស់ខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ដោយមូលហេតុថា កូនក្តីរបស់ខ្ញុំធ្លាប់ជាបុគ្គលិកនៅក្រុមហ៊ុន៧អិនជីពិតប្រាកដមែន ប៉ុន្តែកូនក្តីខ្ញុំបានឈប់ធ្វើការនៅទីនោះ គឺនៅត្រឹមឆ្នាំ២០១៩ ។ កូនក្តីរបស់ខ្ញុំគ្រាន់តែជាអ្នកគក់ជេរដី រាល់ការទិញលក់ផ្តិតស្នាមមេដៃផ្សេងៗ គឺធ្វើនៅក្នុងក្រុមហ៊ុន ពុំមានភស្តុតាងណាដែលបញ្ជាក់ថាកូនក្តីរបស់ខ្ញុំបានរៀបចំ ឬ បានឃុបឃិតគ្នារៀបចំឯកសារផ្ទេរសិទ្ធនោះទេ ។ មួយវិញទៀត អាជ្ញាធរមូលដ្ឋានភូមិឃុំបានបញ្ជាក់ហើយថា រាល់ឯកសារទាំងអស់គឺធ្វើឡើងដោយក្រុមហ៊ុនជាអ្នករៀបចំ ប៉ុន្តែអ្វីដែលគួរកត់សម្គាល់នោះ ឯកសារដែលកូនក្តីរបស់ខ្ញុំ និង សាក្សីទាំងអស់ បានបញ្ជាក់ នោះ គឺ ឯកសារទាំងអស់សុទ្ធតែមានចុះហត្ថលេខា និង បោះត្រាដោយអាជ្ញាធរមូលដ្ឋានរួចរាល់ជាស្រេច ទើបភាគីអ្នកទិញដីទៅផ្តិតមេដៃ ប្រគល់លុយនៅក្នុងក្រុមហ៊ុន ដូចដែលកូនក្តីរបស់ខ្ញុំបានបំភ្លឺជូនក្នុងអង្គសវនាការ ។ ដូចដែលភស្តុតាងដែលខ្ញុំបានដាក់ជូនអង្គសវនការពិនិត្យនោះគឺ ឯកសារលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីទាំងអស់ គឺមានការចុះហត្ថលេខា និង បោះត្រារបស់អាជ្ញាធរភូមិឃុំរួចរាល់ គឺនៅសល់តែស្នាមមេដៃអ្នកទិញ ដែលត្រូវផ្តិតនិងប្រគល់លុយតែប៉ុណ្ណោះ ដោយសារតែប្រជាពលរដ្ឋជឿទុកចិត្តទៅលើឯកសារដែលមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានភូមិឃុំ ដែលជាអាណាព្យាបាលរបស់ប្រជាពលរដ្ឋ បានបញ្ជាក់យ៉ាងច្បាស់ថា ស្នាមមេដៃទាំងនោះគឺជា ស្នាមមេដៃរបស់ភាគី ដែលបានមកផ្តិតមេដៃ នៅចំពោះមុខអាជ្ញាធរផ្ទាល់ ទើបអ្នកទិញមានការជឿទុកចិត្ត



Scanned with CamScanner

ឈានដល់ការទិញលក់នោះ ។ សរុបមក កូនក្តីរបស់ខ្ញុំពុំបានចូលរួមឃុបឃិត ធ្វើឯកសារក្លែង ក៏ដូចជាលួចលក់ដីរបស់ដើមបណ្តឹងនោះទេ ខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យកូនក្តីខ្ញុំបាទស្នើសុំ លោកចៅក្រម មេត្តាសម្រេចឱ្យកូនក្តីរបស់ខ្ញុំរួចផុតពីបទចោទប្រកាន់ ដោយសារកូនក្តីខ្ញុំពុំមាន ពិរុទ្ធភាពនោះទេ ។

៩. លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន ៖ ខ្ញុំបាទសូមគាំទ្រនូវការលើកឡើងរបស់សហភាតារបស់ខ្ញុំ និង សូមបន្ថែមថា ឯកសារលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីទាំងអស់ត្រូវ គឺមានការចុះហត្ថលេខា និង បោះត្រាដោយអាជ្ញាធរមូលដ្ឋាន ព្រមទាំងមានស្នាមមេដៃរបស់ដើមបណ្តឹងឈ្មោះ [redacted] ណារ៉ែត ផងដែរ ដូចនេះទើបកូនក្តីរបស់ខ្ញុំមានការជឿជាក់ទៅលើឯកសារទាំងនោះ ហើយគាត់ក៏មិនអាចដឹងថាស្នាមមេដៃនោះជាស្នាមមេដៃក្លែងក្លាយ ឬ ពិតប្រាកដរបស់ឈ្មោះ [redacted] ណារ៉ែត ហេតុនេះបញ្ជាក់បានថាកូនក្តីខ្ញុំពុំមានពិរុទ្ធភាពពីបទចោទប្រកាន់របស់តំណាងអយ្យការនោះទេ ។ ម្យ៉ាងវិញទៀត នៅក្នុងពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង ក្នុងអង្គសវនការនោះគឺ ដើមបណ្តឹងរដ្ឋប្បវេណី មិនមានបំណងប្តឹងទៅលើកកូនក្តីរបស់ខ្ញុំនោះទេ គឺគាត់មានបំណងប្តឹងទៅលើឈ្មោះ [redacted] វ៉ាវុធ និង ឈ្មោះ [redacted] បញ្ញារិត តែប៉ុណ្ណោះ ។ ពាក់ព័ន្ធនឹងការឈប់ធ្វើការរបស់កូនក្តីខ្ញុំនោះគឺដូចដែលកូនក្តីខ្ញុំបានបញ្ជាក់នោះ គឺគាត់បានឈប់ធ្វើការ បើទោះបីជាការសុំឈប់ធ្វើការរបស់គាត់ គឺតាមរយៈការជូនដំណឹងផ្ទាល់មាត់ ដោយពុំមានលិខិតស្នាមអ្វីនោះក៏ដោយ គឺបំពេញទៅតាមទម្រង់ច្បាប់ដែរ ។ កូនក្តីរបស់ខ្ញុំ ពុំមានជាប់ពាក់ព័ន្ធទៅនឹងក្រុមហ៊ុនទៀតនោះទេ គឺគាត់គ្រាន់តែជាអ្នកគូកជេរដី ដើម្បីទទួលបានប្រាក់កម្លៃជើងសារតែប៉ុណ្ណោះ ។ ដូចនេះ ខ្ញុំបាទតំណាងឱ្យកូនក្តីរបស់ខ្ញុំ ស្នើសុំលោកចៅក្រមសម្រេចលើកលែងកូនក្តីខ្ញុំរួចខ្លួនពីបទចោទ ។

## សំអាងហេតុ

១. ក្រោយពីបានធ្វើការពិភាក្សាដេញដោល សួរចម្លើយរបស់ជនជាប់ចោទ ព្រមទាំងពិនិត្យភស្តុតាងផ្សេងៗ បានបញ្ជាក់ថា ជនជាប់ចោទ ឈ្មោះ [redacted] វ៉ាវុធ ជាអ្នករៀបចំឯកសារផ្ទេរកម្មសិទ្ធិ ដោយបានបន្លំស្នាមមេដៃអ្នកផ្ទេរសិទ្ធិ ហើយឱ្យជនជាប់ចោទ ឈ្មោះ [redacted] បញ្ញារិត យកឯកសារផ្ទេរសិទ្ធិ និង ឯកសារពាក់ព័ន្ធទាំងឡាយដែលបានបន្លំស្នាមមេដៃអ្នកផ្ទេរ និង អ្នកទទួលសិទ្ធិនោះ ប្រើល្បិចកុហកដើម្បីឱ្យអាជ្ញាធរមូលដ្ឋានចុះហត្ថលេខា និង បោះត្រា លើឯកសារផ្ទេរសិទ្ធិដែលពួកខ្លួនបានក្លែងបន្លំទាំងអស់នោះ ។ ចំណែកឯជនជាប់ចោទ ឈ្មោះ [redacted] សុបុត្តា ជាអ្នកនាំអតិថិជន ដែលមានបំណងទិញ ឬ លក់ដី ឱ្យទៅជួបឈ្មោះ [redacted] វ៉ាវុធ និង ឈ្មោះ [redacted] បញ្ញារិត ដើម្បីទិញឬលក់ដីនោះ ។ ផ្អែកតាមចម្លើយបំភ្លឺរបស់ ដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយថា "ខ្លួនពុំដែលធ្លាប់បានផ្តិតមេដៃលើការទិញលក់ និង មិនធ្លាប់ផ្តិតមេដៃលើក្រដាសទុកឱ្យឈ្មោះ [redacted] វ៉ាវុធ លក់ដីឱ្យនោះទេ" ។ ម្យ៉ាងវិញទៀត យោងតាមភស្តុតាងនានា នៅក្នុងសំណុំរឿង ឃើញថា នៅពេលជនជាប់ចោទឈ្មោះ [redacted] សុបុត្តា ទទួលលុយពីអ្នកទិញដី គឺមានចេញវិក័យបត្រទទួលលុយ ប៉ុន្តែពេលប្រគល់លុយឱ្យឈ្មោះ [redacted] វ៉ាវុធ និង ឈ្មោះ [redacted] បញ្ញារិត បែរជាពុំមានលិខិតប្រគល់ទទួលលុយទៅវិញ ព្រមទាំងនិយាយថា ខ្លួនពុំដឹងថាចាំបាច់ត្រូវតែមាន។ គ្រប់ចំណុចទាំងអស់នេះ តុលាការយល់ឃើញថា ជនជាប់ចោទទាំងបិនាក់ ពិតជាបានឃុបឃិតគ្នា លួចលក់ដីរបស់អ្នកដទៃ រៀបចំឯកសារឡើងដោយក្លែងបន្លំស្នាមមេដៃរបស់ម្ចាស់ដី ហើយប្រើប្រាស់ឯកសារជាលិខិតក្លែងបន្លំនោះ (ប្រគល់ឱ្យអ្នកទិញ) ដោយមានចម្លើយ និង ភស្តុតាងស៊ីសង្វាក់ ។



Scanned with CamScanner

២. ជនជាប់ចោទ ជានីតិជន និង មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ។

៣. ជនជាប់ចោទខាងលើបានដឹងថា អំពើរបស់ខ្លួនជាអំពើផ្ទុយច្បាប់ ប៉ុន្តែនៅតែប្រព្រឹត្តផ្ទុយច្បាប់ទៀត ។ ដូចនេះតុលាការយល់ឃើញថា ជនជាប់ចោទមានចេតនាក្នុងការប្រព្រឹត្តបទល្មើស ។

៤. តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទ ដូចមានចែងនៅក្នុងសេចក្តីសន្និដ្ឋានស្ថាពរ និង ស្នើសុំតុលាការចេញដីកាចាប់ខ្លួនជនជាប់ចោទមកផ្តន្ទាទោសតាមច្បាប់ ។ តុលាការនឹងពិចារណាសម្រេចស្របតាម អង្គហេតុ និង អង្គច្បាប់ ។

៥. មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានស្នើសុំតុលាការសម្រេចឱ្យជនជាប់ចោទ រួចខ្លួនពីបទចោទប្រកាន់ ប៉ុន្តែតុលាការយល់ឃើញថា ការស្នើសុំរបស់មេធាវីមិនត្រឹមត្រូវនោះទេ ដោយមានមូលហេតុដូចមានក្នុងសំអាងហេតុទី ១ ខាងលើ ។

៦. ក្រោយពីឆ្លងកាត់ការពិភាក្សាដេញដោល និង ពិនិត្យភស្តុតាងនានា តុលាការយល់ឃើញថា ជនជាប់ចោទ ឈ្មោះ [redacted] រ៉ាវុធ ភេទស្រី កើតឆ្នាំ ១៩៨៥ ឈ្មោះ [redacted] **បញ្ញារិត** ភេទប្រុស កើតឆ្នាំ ១៩៨៧ ឈ្មោះ [redacted] **សុបុត្តា** ភេទប្រុស កើតឆ្នាំ ១៩៩១ បានប្រព្រឹត្ត **បទក្លែងបន្លំ បទប្រើប្រាស់លិខិតក្លែង និង បទលួចលក់អចលនវត្ថុរបស់អ្នកដទៃ** ប្រព្រឹត្តនៅភូមិស្វាយមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៦២៦ មាត្រា ៦២៧ មាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

៧. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ណារ៉ែត** បានទាមទារសំណងខូចខាតចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក និង សំណងជម្ងឺចិត្តចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ប៉ុន្តែតុលាការពិនិត្យឃើញថា ពាក់ព័ន្ធសំណងការខូចខាត ដើមបណ្តឹងរដ្ឋប្បវេណីពុំបានបង្ហាញភស្តុតាងថា ការខូចខាតជាក់ស្តែងមានចំនួនប៉ុន្មាននោះទេ។ ដូចនេះតុលាការនឹងពិចារណា សម្រេចអំពីសំណងការខូចខាត និង ជម្ងឺចិត្ត ក្នុងកម្រិតសមរម្យ ។

## ហេតុដូច្នេះសម្រេច

១. ផ្តន្ទាទោស

ក. ឈ្មោះ [redacted] **រ៉ាវុធ** ភេទស្រី ៣៨ឆ្នាំ (សាវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ

ខ. ឈ្មោះ [redacted] **បញ្ញារិត** ភេទប្រុស ៣៦ឆ្នាំ (សាវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ

គ. ឈ្មោះ [redacted] **សុបុត្តា** ភេទប្រុស ៣១ឆ្នាំ (សាវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ

ពី **បទក្លែងបន្លំ បទប្រើប្រាស់លិខិតក្លែង និង បទលួចលក់អចលនវត្ថុរបស់អ្នកដទៃ** ប្រព្រឹត្តនៅភូមិស្វាយមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៦២៦ មាត្រា ៦២៧ មាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ២៥៥ នៃច្បាប់ភូមិបាល ។



Scanned with CamScanner

២. បង្គាប់ឱ្យជនជាប់ចោទ

ក. ឈ្មោះ [redacted] រ៉ាវុធ ភេទស្រី ៣៨ឆ្នាំ (សាវតាជាតិខាងលើ)

ខ. ឈ្មោះ [redacted] បញ្ញារិត ភេទប្រុស ៣៦ឆ្នាំ (សាវតាជាតិខាងលើ)

គ. ឈ្មោះ [redacted] សុបុត្តា ភេទប្រុស ៣១ឆ្នាំ (សាវតាជាតិខាងលើ)

រួមគ្នាសងសំណងចំនួន ០៣ (បី) ម៉ឺន ដុល្លារអាមេរិក ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណារ៉ែណត ភេទស្រី អាយុ ៤៩ឆ្នាំ ។

សាលក្រមនេះ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុបុត្តា ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណារ៉ែណត កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] រ៉ាវុធ និង ឈ្មោះ [redacted] បញ្ញារិត ។ ទុកសិទ្ធិប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ តាមនីតិវិធីច្បាប់។

ថ្ងៃព្រហស្បតិ៍ ៩ រោច ខែទុតិយសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្តាល, ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

ហត្ថលេខា និង ត្រា [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និង ត្រា [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៩ រោច ខែទុតិយសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្តាល, ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner